ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*** ⚖ ***

សាលាដំបូងខេត្តព្រះសីហនុ
សំណុំរឿងរដ្ឋប្បវេណីលេខ: ១៧៥
ចុះថ្ងៃទី១៣.០៧.២០២២

<u>សាលក្រម</u>

លេខ: ១៣៤/១៣ "ញ"
ចុះថ្ងៃទី០១.១១.២០២២

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះសីហនុ**

**បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ សាលក្រមប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២។**

-លោក[redacted] ចៅក្រមនៃសាលាដំបូងខេត្តព្រះសីហនុ។
-លោក[redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តព្រះសីហនុ។

**រវាង** សហដើមចោទ៖

១-ឈ្មោះ[redacted]វិសិទ្ធ ភេទប្រុស កើតថ្ងៃទី២៥.១២.១៩៤៨ កាន់អត្តសញ្ញាណប័ណ្ណលេខ:[redacted] និងប្រពន្ធឈ្មោះ[redacted] ចាន់ ភេទស្រី កើតថ្ងៃទី[redacted] កាន់អត្តសញ្ញាណប័ណ្ណលេខ:[redacted] មានអាសយដ្ឋាននៅផ្ទះលេខ:[redacted]

២-ឈ្មោះ[redacted]មុយលី ភេទស្រី កើតថ្ងៃទី[redacted] កាន់អត្តសញ្ញាណប័ណ្ណលេខ:[redacted]។

-តំណាងដោយអាណត្តិឲ្យសហដើមចោទមេធាវី[redacted]។

**និង** ចុងចម្លើយ៖ឈ្មោះ[redacted] XIKUN សញ្ជាតិចិន កើតថ្ងៃទី[redacted] កាន់លិខិតឆ្លងដែនលេខ[redacted]ធ្វើនៅHUNAN ផុតកំណត់នៅថ្ងៃទី[redacted] មានអាសយ[redacted]

**-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖**

-សុំឲ្យតុលាការចេញសាលក្រម៖

១-រំលាយកិច្ចសន្យាជួលអចលវត្ថុ(ដី) ចុះថ្ងៃទី[redacted] រវាងសហដើមចោទឈ្មោះ[redacted]វិសិទ្ធ,ឈ្មោះ[redacted] ចាន់,ឈ្មោះ[redacted]មុយលី និងចុងចម្លើយឈ្មោះ[redacted] XIKUN។

២-បង្គាប់ឲ្យចុងចម្លើយប្រគល់ដីទីតាំងជួលអចលនវត្ថុ(ដី) ដែលមានក្បាលដីលេខ:១៩១ ផ្ទៃដីសរុប ១០៦៣៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩១ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ:៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ និងក្បាលដីលេខ:១៩២ ផ្ទៃដីសរុប១៣៧០៧ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ:៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ មកឲ្យសហដើមចោទវិញ។

៣-រឹបអូសប្រាក់កក់ចំនួន១៤៦០៦៤០$ (មួយលានបួនសែនប្រាំមួយម៉ឺនប្រាំមួយរយសែសិប) ដុល្លារអាមេរិក ឲ្យមកសហដើមចោទវិញ។

៤-ឲ្យសហដើមចោទមានសិទ្ធិគ្រប់គ្រង ជាម្ចាស់កម្មសិទ្ធិករលើសំណង់ទាំងអស់របស់ចុងចម្លើយដែលមាននៅលើទីតាំងជួលអចលនវត្ថុ(ដី) ទាំងពីរកន្លែង ដែលស្ថិតនៅលើក្បាលដីលេខ:១៩១ ផ្ទៃដីសរុប ១០៦៣៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩១ ចុះ



Scanned with CamScanner

ថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ និងក្បាលដីលេខ:១៩២ផ្ទៃដីសរុប១៣៧០៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ:៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ។

៥-បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ឈ្នួលដែលខកខានបង់ចាប់តាំងពីខែធ្នូ ឆ្នាំ២០១៩ ដល់ខែឧសភា ឆ្នាំ២០២២ មានចំនួន២៩ខែ ស្មើនឹងទឹកប្រាក់សរុបចំនួន៣៥២៩៨៨០$(បីលានប្រាំសែនពីរម៉ឺនប្រាំបួនពាន់ប្រាំបីរយប៉ែតសិប) ដុល្លារអាមេរិក មកឲ្យសហដើមចោទ។

៦-ទាមទារសំណងការខូចខាតពេលវេលាជំងឺចិត្ត និងសេវាមេធាវីចំនួន៣០០០០$(បីម៉ឺន) ដុល្លារអាមេរិក។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

## អង្គហេតុ និងចំណុចវិវាទ

### ១.អង្គហេតុ

-កាលពីថ្ងៃទី០៦.០៨.២០១៨ សហដើមចោទបានចុះកិច្ចសន្យាជួលទីតាំងដីចំនួនពីរកន្លែង៖ដែលទី១ មានក្បាលដីលេខ:១៩១ ផ្ទៃដីសរុប១០៦៣៧ម៉ែត្រការ៉េ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ១៨០១០៤០៤-០១៩១ និងទី២មានក្បាលដីលេខ:១៩២ផ្ទៃដីសរុបចំនួន១៣៧០៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩២ មានទីតាំងស្ថិតនៅភូមិ៤ សង្កាត់លេខ: ៤ ខណ្ឌមិត្តភាព(ក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ ជាមួយនឹងចុងចម្លើយដើម្បីប្រកបអាជីវកម្មស្របច្បាប់នៅប្រទេសកម្ពុជាដែលកិច្ចសន្យានេះមានរយៈពេល១៤ឆ្នាំ។ ក្រោយពេលជួលបានមួយរយៈស្រាប់តែនៅឆ្នាំ២០១៩ ភាគីចុងចម្លើយឈ្មោះ[redacted] XIKUN ពុំបានអនុវត្តកាតព្វកិច្ចបង់ប្រាក់ឈ្នួលប្រចាំខែទៅឲ្យភាគីសហដើមចោទតាមកិច្ចសន្យាជួលខាងលើឡើយ ទោះបីជាភាគីសហដើមចោទជូនដំណឹងដាស់តឿនជាច្រើនដងរួចហើយក៏ដោយ ប៉ុន្តែចុងចម្លើយនៅតែមិនព្រមអនុវត្តកាតព្វកិច្ចបង់ប្រាក់ឈ្នួលដដែល។ ក្រោយមកភាគីសហដើមចោទឈ្មោះ[redacted] វិសិទ្ធ,ឈ្មោះ[redacted] ចាន់ និងឈ្មោះ[redacted] មុយលី ក៏បានធ្វើការដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តព្រះសីហនុ តែម្តងទៅ។

### ២.សេចក្តីថ្លែងការណ៍របស់គូភាគី

-លោកស្រីមេធាវី[redacted]ជាមេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្លួនសូមរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៥.០៦.២០២២,កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២៩.០៨.២០២២ និងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី០៥.០៩.២០២២ ទុកជាបានការទាំងស្រុង។ ខ្លួនសូមធ្វើសេចក្តីថ្លែងការណ៍បន្ថែមថា: កូនក្តីខ្លួនបានទទួលដំណឹងអំពីការចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី០៤.១០.២០២២ វេលាម៉ោង០២ និង៣០នាទី នេះរួចហើយ និងមូលហេតុដែលកូនក្តីខ្លួនប្តឹងសុំឲ្យតុលាការចេញសាលក្រមរំលាយកិច្ចសន្យាជួលអចលនវត្ថុ(ដី) ចុះថ្ងៃទី០៦.០៨.២០១៨ រវាងសហដើមចោទឈ្មោះ[redacted] វិសិទ្ធិ,ឈ្មោះ[redacted] ចាន់,ឈ្មោះ[redacted] មុយលី ជាមួយចុងចម្លើយឈ្មោះ[redacted] XIKUN និងទាមទារឲ្យចុងចម្លើយប្រគល់ទីតាំងជួលខាងលើដែលមានក្បាលដីលេខ១៩១ និងលេខ១៩២ ដែលមានទីតាំងស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មកឲ្យកូនក្តីខ្លួនជាសហដើមចោទវិញ ដោយហេតុថា:ចុងចម្លើយឈ្មោះ[redacted] XIKUN បំពានកិច្ចសន្យាត្រង់ប្រការ៧.៣ និងប្រការ១១.១ ដោយចុងចម្លើយបានខកខានបង់ប្រាក់ឈ្នួលចាប់តាំងពីខែធ្នូ ឆ្នាំ២០១៩ រហូតដល់ពេលបច្ចុ

ប្បន្ននេះ ដែលការខកខាននេះលើសចំនួន៦០ថ្ងៃ ដែលគូភាគីបានព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យាជួលត្រង់ប្រការ១១.១ ហើយផ្អែកតាមប្រការ៧.៣និងប្រការ១១.១ នៃកិច្ចសន្យាគឺកូនក្តីខ្លួនមានសិទ្ធិរំលាយកិច្ចសន្យាជួលមុនកំណត់។ ម្យ៉ាងវិញទៀតផ្អែកតាមមាត្រា៤០៧ និងមាត្រា៤០៨ នៃក្រមរដ្ឋប្បវេណីក៏បានបើកសិទ្ធិឲ្យកូនក្តីខ្លួនប្តឹងរំលាយកិច្ចសន្យាជួលខាងលើនេះតាមច្បាប់ផងដែរ។ ចំពោះការស្នើសុំឲ្យមានរឹបអូសប្រាក់កក់ និងសិទ្ធិគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ(ដី) ទាំងពីរកន្លែងដែលមានក្បាលដីលេខៈ១៩១ និងលេខៈ១៩២ ស្ថិតនៅភូមិ៤ សង្កាត់លេខៈ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ តាមការព្រមព្រៀងនៃកិច្ចសន្យាជួលអចលនវត្ថុ ចុះថ្ងៃទី០៦.០៨.២០១៨ ត្រង់ប្រការ៨.២ និងប្រការ ១១.១ ដែលបានចែងថាៈ"ក្នុងករណីដែលភាគីខ(ចុងចម្លើយ) បញ្ឈប់ការជួលមុនពេលកំណត់វិញនេះប្រាក់កក់ទាំងអស់ដូចមានចែងក្នុងប្រការ៤ និងក្លាយជាកម្មសិទ្ធិរបស់ភាគី(ដើមចោទ) ដោយគ្មានការតវ៉ា។ ភាគី(ខ) ត្រូវទទួលខុសត្រូវនូវការបង់សេវាផ្សេងៗដែលមិនទាន់បានទូរទាត់រួច។ ខ្លួនសូមបញ្ជាក់បន្ថែមថាៈ ក្រោយពីចុះកិច្ចសន្យាជួលរួចមកកូនក្តីខ្លួនបានអនុគ្រោះប្រាក់ឈ្នួលចំនួន ១២ខែ គិតចាប់ពីថ្ងៃចុះកិច្ចសន្យាជួលថ្ងៃទី០៦.០៨.២០១៨ រហូតដល់ថ្ងៃទី០៦.០៨.២០១៩ ហើយស្រាប់តែចាប់ពីខែធ្នូ ឆ្នាំ២០១៩ ចុងចម្លើយក៏ឈប់បង់ប្រាក់ឈ្នួលមកឲ្យកូនក្តីខ្លួនទៀតទោះបីជាមានការជូនដំណឹងជាស់តឿនក៏ដោយរហូតដល់ថ្ងៃដាក់ពាក្យបណ្តឹងមានរយៈពេល២៩ខែមកហើយ។

សំណូមពរសុំឲ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១-រំលាយកិច្ចសន្យាជួលអចលវត្ថុ (ដី) ចុះថ្ងៃទី០៦.០៨.២០១៨ រវាងសហដើមចោទឈ្មោ[redacted] វិសិទ្ធ,ឈ្មោះ[redacted] ចាន់,ឈ្មោះ[redacted]មុយលី និងចុងចម្លើយឈ្មោ[redacted]XIKUN។

២-បង្គាប់ឲ្យចុងចម្លើយប្រគល់ដីទីតាំងជួលអចលនវត្ថុ(ដី) ដែលមានក្បាលដីលេខៈ១៩១ផ្ទៃដីសរុប១០៦៣៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៨០១០៤០៤-០១៩១ ចុះថ្ងៃទី២៣.០៦.២០០៦ស្ថិតនៅភូមិ៤ សង្កាត់លេខៈ៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ និងក្បាលដីលេខៈ១៩២ផ្ទៃដីសរុប១៣៧០៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ មកឲ្យសហដើមចោទវិញ។

៣-រឹបអូសប្រាក់កក់ចំនួន១៤៦០៦៤០ (មួយលានបួនសែនប្រាំមួយម៉ឺនប្រាំមួយរយសែសិប) ដុល្លារអាមេរិក ឲ្យមកសហដើមចោទវិញ។

៤-ឲ្យសហដើមចោទមានសិទ្ធិគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិករ លើសំណង់ទាំងអស់របស់ចុងចម្លើយដែលមាននៅលើទីតាំងជួលអចលនវត្ថុ(ដី) ទាំងពីរកន្លែងដែលស្ថិតនៅលើក្បាលដីលេខៈ១៩១ ផ្ទៃដីសរុប១០៦៣៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៨០១០៤០៤-០១៩១ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ និងក្បាលដីលេខៈ១៩២ ផ្ទៃដីសរុប១៣៧០៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខៈ៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ។

៥-បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ឈ្នួលដែលខកខានបង់ចាប់តាំងពីខែធ្នូ ឆ្នាំ២០១៩ ដល់ខែឧសភា ឆ្នាំ២០២២ មានចំនួន២៩ខែ ស្មើនឹងទឹកប្រាក់សរុបចំនួន៣៥២៩៨៨០ (បីលានប្រាំសែនពីរម៉ឺនប្រាំបួនពាន់ប្រាំបីរយប៉ែតសិប) ដុល្លារអាមេរិក មកឲ្យសហដើមចោទ។

៦-ទាមទារសំណងការខូចខាតពេលវេលាជំងឺចិត្ត និងសេវាមេធាវីចំនួន៣០០០០(បីម៉ឺន) ដុល្លារអា

មេរិក។

៧-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចុងចម្លើយ។

-លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទធ្វើសេចក្ដីថ្លែងការណ៍ថា: ខ្លួនសូមឯកភាពតាមការលើកឡើងរបស់សហភាគីរបស់ខ្លួនទាំងស្រុង។

-ចុងចម្លើយឈ្មោះ [redacted] XIKUN បានអវត្តមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅពេលនេះ បើទោះបីជាតុលាការបានធ្វើការបញ្ជូនដីកាកោះតាមលិខិតជូនដំណឹងអំពីការបញ្ជូនតាមការផ្សាយជាសាធារណៈលេខៈ៣១១៦ រប/ញ/២២ ចុះថ្ងៃទី១២.០៩.២០២២ ត្រឹមត្រូវតាមនីតិវិធីរួចហើយក៏ដោយ។

**៣.ការពិនិត្យភស្តុតាងជាឯកសាររួមមានៈ**

**ក**-កិច្ចសន្យាជួលអចលនវត្ថុ(ដី) ចុះថ្ងៃទី០៦.០៨.២០១៨ របស់ឈ្មោះ [redacted] វិសិទ្ធ,ឈ្មោះ [redacted] ចាន់, ឈ្មោះលី មុយលី ជាមួយឈ្មោះ [redacted] XIKUN។

**ខ**-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៨០១០៤០៤-០១៩១ ចុះថ្ងៃទី២៣.០៦.២០០៦ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។

**គ**-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣.០៦.២០០៦ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។

**ឃ**-លិខិតជូនដំណឹង ចុះថ្ងៃទី២៩.០១.២០២០ របស់ឈ្មោះ [redacted] វិសិទ្ធ។

**ង**-លិខិតជូនដំណឹង ចុះថ្ងៃទី០៥.០២.ឆ្នាំ២០២០ របស់ឈ្មោះ [redacted] XIKUN។

**ច**-លិខិតជូនដំណឹង ចុះថ្ងៃទី២៥.០២.២០២០ របស់ឈ្មោះ [redacted] វិសិទ្ធ។

**ឆ**-លិខិតឆ្លើយតប ចុះថ្ងៃទី១៧.០៣.២០២០ របស់លោកមេធាវី [redacted]។

**ជ**-លិខិតជូនដំណឹង ចុះថ្ងៃទី១៥.០៧.២០២០ របស់ឈ្មោះ [redacted] វិសិទ្ធ។

**៥.ចំណុចវិវាទៈ** គ្មាន។

## <u>សំអាងហេតុ</u>

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថាៈ

១-តាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទឃើញថា: កាលពីថ្ងៃទី០៦.០៨.២០១៨ កូនក្ដីរបស់ខ្លួនបានចុះកិច្ចសន្យាជួលអចលនវត្ថុ(ដី) ចំនួនពីរកន្លែងដែលស្ថិតនៅលើក្បាលដីលេខៈ១៩១ផ្ទៃដីសរុប១០៦៣៧ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៨០១០៤០៤-០១៩១ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ និងក្បាលដីលេខៈ១៩២ ផ្ទៃដីសរុប១៣៧០៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ ឲ្យទៅចុងចម្លើយឈ្មោះ [redacted] XIKUN ដែលមានថ្លៃឈ្នួលក្នុងមួយម៉ែត្រការ៉េតំលៃ០៥(ប្រាំ)ដុល្លាអាមេរិក ក្នុងមួយខែ និងមានរយៈពេលជួលចំនួន១៤ឆ្នាំ ដែលការថ្លែងការណ៍នេះមានភាពស៊ីចង្វាក់ជាមួយកិច្ចសន្យាជួលអចលនវត្ថុ(ដី) ចុះថ្ងៃទី០៦.០៨.២០១៨ អាចឲ្យតុលាការជឿជាក់បាន។ ម្យ៉ាងវិញទៀត មេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទបានថ្លែងការណ៍បន្ថែមថា: ក្រោយពេលជួលបានមួយរយៈស្រាប់តែនៅខែធ្នូ ឆ្នាំ២០១៩ ភាគីចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចបង់ប្រាក់ឈ្នួលប្រចាំខែ មកឲ្យភាគីសហដើមចោទតាមកិច្ចសន្យា

នោះទេ ទោះបីជាសហដើមចោទបានជូនដំណឹងជាច្រើនលើកច្រើនសារួចហើយក៏ដោយ ដែលអំពើរបស់ចុងចម្លើយបានបំពានខ្លឹមសារនៃកិច្ចសន្យាជួលអចលនវត្ថុ(ដី) ចុះថ្ងៃទី០៦.០៨.២០១៨ ត្រង់ប្រការ៧.៣ និងប្រការ១១.១ នៃកិច្ចសន្យា។ ដូច្នេះ តាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទ និងការពិនិត្យភស្តុតាងជាឯកសារនូវៈកិច្ចសន្យាជួលអចលនវត្ថុ(ដី) ចុះថ្ងៃទី០៦.០៨.២០១៨ ,លិខិតជូនដំណឹង ចុះថ្ងៃទី២៩.០១.ឆ្នាំ២០២០,លិខិតជូនដំណឹង ចុះថ្ងៃទី០៥.០២.២០២០,លិខិតជូនដំណឹង ចុះថ្ងៃទី២៥.០២.២០២០,លិខិតឆ្លើយតប ចុះថ្ងៃទី១៧.០៣.២០២០ និងលិខិតជូនដំណឹង ចុះថ្ងៃទី១៥.០៧.២០២០ ឃើញថា: សកម្មភាពរបស់ចុងចម្លើយខកខានក្នុងការបង់ប្រាក់ឈ្នួលប្រចាំខែ បានផ្ទុយប្រការ៧.៣ និងប្រការ១១.១ នៃកិច្ចសន្យាជួលអចលនវត្ថុ(ដី) ជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរស្របតាមមាត្រា៤០៧ និង មាត្រា៤០៨ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

២-មេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទបានថ្លែងការណ៍ថា: មូលហេតុដែលនាំឲ្យរំលាយកិច្ចសន្យាជួលអចលនវត្ថុ(ដី) ចុះថ្ងៃទី០៦.០៨.២០១៨ គឺកើតចេញពីកំហុសរបស់ចុងចម្លើយ។ ដូច្នេះ ផ្អែកតាមមាត្រា៤១១ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងអានុភាពនៃការរំលាយកិច្ចសន្យាដែលកើតចេញពីកំហុសរបស់ចុងចម្លើយតម្រូវឲ្យមានករណីយកិច្ចសងការខូចខាត។ ម្យ៉ាងវិញទៀត ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទ និងការពិនិត្យភស្តុតាងជាឯកសារនូវៈកិច្ចសន្យាជួលអចលនវត្ថុ(ដី) ចុះថ្ងៃទី០៦.០៨.២០១៨ ត្រង់ប្រការ៧.៣ និងប្រការ១១.១ ឃើញថា:ចុងចម្លើយបានព្រមព្រៀងជាមួយសហដើមចោទថា: ក្នុងករណីដែលចុងចម្លើយខកខាន ឬបដិសេធមិនបង់ថ្លៃឈ្នួលតាមកិច្ចសន្យានោះក្នុងរយៈពេល៦០ (ហុកសិប)ថ្ងៃ នោះកិច្ចសន្យានេះនឹងត្រូវទុកជាមោឃៈហើយប្រាក់កក់ទាំងអស់នឹងក្លាយជាកម្មសិទ្ធិរបស់សហដើមចោទដោយគ្មានការតវ៉ា។ ហើយចុងចម្លើយព្រមប្រគល់ទីតាំងជួលដីនិងសំណង់ផ្សេងៗ ដែលចុងចម្លើយបានសាងសង់នឹងទ្រព្យអកម្មជូនមកសហដើមចោទដោយមិនទាមទារសំណងអ្វី ឬយកហេតុផលណាមួយមកពន្យាពេលឡើយ និងត្រង់ប្រកា៨.២ នៃកិច្ចសន្យាបានចែងថា:ក្នុងករណីដែលចុងចម្លើយបញ្ឈប់ការជួលមុនពេលកំណត់វិញនោះ ប្រាក់កក់ទាំងអស់នឹងក្លាយទៅជាកម្មសិទ្ធិរបស់សហដើមចោទដោយគ្មានការតវ៉ា ហើយចុងចម្លើយត្រូវទទួលខុសត្រូវក្នុងការបង់ថ្លៃសេវាកម្មផ្សេងៗ ដែលមិនទាន់បានទូទាត់រួច មិនឲ្យជាប់ពាក់ព័ន្ធនឹងសហដើមចោទឡើយ។ គប្បី តុលាការទទួលស្គាល់ការទាមទាររបស់សហដើមចោទត្រង់ចំណុច ឲ្យចុងចម្លើយបង់ប្រាក់ឈ្នួលចំនួន៣៥២៩៨៨០$(បីលានប្រាំសែនពីរម៉ឺនប្រាំបួនពាន់ប្រាំបីរយប៉ែតសិប) ដុល្លារអាមេរិក និងរឹបអូសប្រាក់កក់ដូចមានចែងក្នុងកិច្ចសន្យាជួលអចលនវត្ថុ (ដី) ចុះថ្ងៃទី០៦.០៨.២០១៨ នឹងការទាមទារឲ្យចុងចម្លើយប្រគល់សំណង់ទាំងអស់របស់ចុងចម្លើយដែល មាននៅលើទីតាំងជួលអចលនវត្ថុ(ដី) ទាំងពីរកន្លែងដែលស្ថិតនៅលើក្បាលដីលេខ:១៩១ផ្ទៃដីសរុប ១០៦៣៧ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩១ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ:៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ និងក្បាលដីលេខ:១៩២ផ្ទៃដីសរុប១៣៧០៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣.០៦.២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ ឲ្យមកសហដើមចោទ។

៣-ចុងចម្លើយបានអវត្តមាននាពេលទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០៤.១០.២០២២ ទោះបីជាតុលាការបញ្ជូនដីកាកោះឲ្យចូលរួមត្រឹមត្រូវតាមនីតិវិធីក៏ដោយ។ ដូច្នេះ ការអវត្តមានរបស់ចុងចម្លើយត្រូវចាត់ទុកថា: ចុងចម្លើយបានសារភាពតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ

ដែលជាមូលហេតុនៃការប្តឹងទាមទារ។ គប្បី តុលាការទទួលស្គាល់ស្របតាមមាត្រា១២៣ និងមាត្រា២០១ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

៤-ចំពោះការទាមទាររបស់សហដើមចោទឲ្យចុងចម្លើយសងសំណងជម្ងឺចិត្ត និងសេវាមេធាវី ៣០០០០(បីម៉ឺន) ដុល្លារអាមេរិក។ គប្បី តុលាការពិចារណាទៅតាមភាពជាក់ស្តែងដោយធៀបជាមួយព្យសនកម្មដែលសហដើមចោទបានទទួលរងការខូចខាត។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី។ តាមមាត្រា៦៤ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-រំលាយកិច្ចសន្យាជួលអចលវត្ថុ (ដី) ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨ រវាងឈ្មោះ[redacted]វិសិទ្ធ,ឈ្មោះ[redacted]ចាន់,ឈ្មោះ[redacted] មុយលី និងឈ្មោះ[redacted] XIKUN។

២-បង្គាប់ឲ្យឈ្មោះ[redacted] XIKUN ភេទប្រុស ប្រគល់ដីទីតាំងជួលអចលនវត្ថុ(ដី) ដែលមានក្បាលដីលេខ:១៩១ផ្ទៃដីសរុប១០៦៣៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩១ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ:៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ និងក្បាលដីលេខ:១៩២ផ្ទៃដីសរុប១៣៧០៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ:៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ មកឲ្យឈ្មោះ[redacted]វិសិទ្ធ, ឈ្មោះ[redacted]ចាន់,ឈ្មោះ[redacted]មុយលី។

៣-ប្រាក់កក់ចំនួន១៤៦០៦៤០$(មួយលានបួនសែនប្រាំមួយម៉ឺនប្រាំមួយរយសែសិប) ដុល្លារអាមេរិក ដែលចុងចម្លើយឈ្មោះ[redacted] XIKUN បានបង់ឲ្យសហដើមចោទឈ្មោះ[redacted] វិសិទ្ធ,ឈ្មោះ[redacted] ចាន់, ឈ្មោះ[redacted] មុយលី ត្រូវបានជាកម្មសិទ្ធិរបស់សហដើមចោទឈ្មោះ[redacted] វិសិទ្ធ,ឈ្មោះ[redacted] ចាន់,ឈ្មោះ[redacted] មុយលី។

៤-ឲ្យសហដើមចោទមានសិទ្ធិគ្រប់គ្រង ជាម្ចាស់កម្មសិទ្ធិករលើសំណង់ទាំងអស់របស់ចុងចម្លើយ ដែលមាននៅលើទីតាំងជួលអចលនវត្ថុ(ដី) ទាំងពីរកន្លែងដែលស្ថិតនៅលើក្បាលដីលេខ:១៩១ ផ្ទៃដីសរុប១០៦៣៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:១៨០១០៤០៤-០១៩១ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ:៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ និងក្បាលដីលេខ:១៩២ ផ្ទៃដីសរុប១៣៧០៧ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់ អចលនវត្ថុលេខ:១៨០១០៤០៤-០១៩២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្ថិតនៅភូមិ៤ សង្កាត់លេខ:៤ ខណ្ឌមិត្តភាព (បច្ចុប្បន្នក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ។

៥-បង្គាប់ឲ្យចុងចម្លើយឈ្មោះ[redacted] XIKUN បង់ប្រាក់ឈ្នួលដែលខកខានបង់ចាប់តាំងពីខែធ្នូ ឆ្នាំ២០១៩ ដល់ខែឧសភា ឆ្នាំ២០២២ មានចំនួន២៩ខែ ស្មើនឹងទឹកប្រាក់សរុបចំនួន៣៥២៩៨៨០$(បីលានប្រាំសែនពីរម៉ឺនប្រាំបួនពាន់ប្រាំបីរយប៉ែតសិប) ដុល្លារអាមេរិក មកឲ្យសហដើមចោទឈ្មោះ[redacted] វិសិទ្ធ,ឈ្មោះ[redacted]ចាន់,ឈ្មោះ[redacted] មុយលី។

៦-បង្គាប់ឲ្យចុងចម្លើយសងសំណងការខូចខាតពេលវេលាជំងឺចិត្ត និងសេវាមេធាវីចំនួន១០០០០$ (មួយម៉ឺន) ដុល្លារអាមេរិក មកឲ្យសហដើមចោទ។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តព្រះសីហនុថ្ងៃទី០២..ខែ១១...ឆ្នាំ២០២២
ក្រឡាបញ្ជី
[redacted]

ចៅក្រម
[redacted]



Scanned with CamScanner